អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១០

# សេចក្តីអញ្ជើញចូលរួមក្នុងសវនាការរបស់អង្គបុរេជំនុំជម្រះនៃអ.វ.ត.ក

ថ្ងៃទី១១,១២ និង១៥ ខែកុម្ភៈ ឆ្នាំ២០១០

អង្គបុរេជំនុំជម្រះ នៃអ.វ.ត.ក បានកំណត់ថ្ងៃបើកសវនាការសាធារណៈ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងការបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ  អៀង សារី  ខៀវ សំផន  និងអៀង ធីរិទ្ធ នាថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០១០។

អង្គបុរេជំនុំជម្រះបានសំរេច និងអនុញ្ញាតឲ្យមានការផ្សាយបន្តផ្ទាល់ពីដំណើរការសវនាការទៅដល់ស្ថានីយវិទ្យុ និងទូរទស្សន៍សំរាប់ផ្សព្វផ្សាយជាសាធារណៈ។ តំណាងប្រព័ន្ធសារព័ត៌មាននីមួយៗនិងសាធារណៈជនទូទៅនឹងត្រូវបានអញ្ជើញឲ្យចូលរួមដោយផ្ទាល់នៅក្នុងសវនាការនោះ ។

ថ្ងៃព្រហស្បតិ៍ ទី ១១ ខែកុម្ភៈ ឆ្នាំ២០១០ : សំណុំរឿងរបស់ អៀង សារី

ថ្ងៃសុក្រ ទី ១២ ខែកុម្ភៈ ឆ្នាំ២០១០ : សំណុំរឿងរបស់ ខៀវ សំផន

ថ្ងៃច័ន្ទ ទី ១៥ ខែកុម្ភៈ ឆ្នាំ២០១០ : សំណុំរឿងរបស់ អៀង ធីរិទ្ធ

សវនាការនឹងចាប់ផ្តើមនាវេលាម៉ោង ៩:០០ព្រឹក នៅថ្ងៃទី១១,១២ និង១៥ ខែកុម្ភៈ  និងថ្ងៃផ្សេងបន្តបន្ទាប់ទៀតដែលកំណត់ដោយចៅក្រម។  អ្នកចូលរួមទាំងអស់ត្រូវមានវត្តមាននៅកន្លែងអង្គុយដែលបំរុងទុករយៈពេល ៣០ នាទីមុនពេលសវនាការចាប់ផ្តើម នាថ្ងៃទី   ១១  ១២  និង១៥ ខែកុម្ភៈ ។

អ្នកចូលរួមទាំងអស់គំរូវឲ្យមកដល់បរិវេណអ.វ.ត.កក្នុងចន្លោះពីម៉ោង ៧:៣០ ព្រឹកដល់ម៉ោង៨:០០ព្រឹក ដើម្បីទុកពេលឲ្យសន្តិសុខធ្វើការត្រួតពិនិត្យនិងចេញប័ណ្ណ។ ក្លោងទ្វាមុខនឹងបិទនៅវេលាម៉ោង៨:៤៥ ព្រឹក ឬនៅពេលដែលកន្លែងអង្គុយនៅក្នុងសាលសវនាការពេញអស់។

អ្នកចូលរួមទាំងអស់ត្រូវបង្ហាញអត្តសញ្ញាណសំគាល់ដែលមានភ្ជាប់រូបថត ហើយត្រូវឆ្លងកាត់ការត្រួតពិនិត្យផែកឆេររបស់សន្តិសុខ។ សូមកត់សំគាល់ផងដែរថា បុគ្គលក្រោមអាយុ១៦ឆ្នាំ នឹងមិនអនុញ្ញាតិឲ្យចូលក្នុងសាល

CETC, Rue Nationale 4, Commune: Chaom Chao, District: Dangkao PO Box 71, Phnom Penh, Cambodge
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh

សវនាការនោះទេ។ ទូរស័ព្ទ កាបូបធំៗ ចំណីអាហារនិង ភេសជ្ជៈ នឹងត្រូវហាមឃាត់មិនអោយនាំចូលក្នុងសាលសវនាការនោះទេ។

សាធារណៈជនទូទៅត្រូវបានលើកទឹកចិត្តក្នុងការចុះឈ្មោះជាមុនហើយអ្នកដែលមកមុននឹងទទួលបានកន្លែងអង្គុយមុន។ កន្លែងអង្គុយសំរាប់សាធារណៈជនមានបំរុងទុកចំនួន ១០០ កន្លែង។ ក្នុងករណីលោកអ្នកត្រូវការធ្វើដំណើរតាមរថយន្តក្រុងរបស់អ.វ.ត.ក ដោយឥតគិតថ្លៃ គឺលោកអ្នកត្រូវធ្វើការចុះឈ្មោះជាមុន។

**មធ្យោបាយធ្វើដំណើរ** ៖ អ.វ.ត.ក នឹងផ្តល់សេវាកម្មធ្វើដំណើរដោយឥតគិតថ្លៃសំរាប់អ្នកសារព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណៈជនដែលមិនមានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនទាំងទៅនិងមកកាន់ អ.វ.ត.ក។ រថយន្តក្រុងនឹងចាកចេញពីមុខស្ថានីយរាជាយស្ម័យានពីចន្លោះម៉ោង ៧:៣០ព្រឹក ដល់ម៉ោង៨:០០ព្រឹក នៅរាល់ថ្ងៃសវនាការ។ សំរាប់អ្នកត្រូវការសេវាកម្មនេះ គឺទាមទារឲ្យមានការចុះឈ្មោះជាមុន។

អ.វ.ត.ក មានទីតាំងស្ថិតនៅសង្កាត់ចោមចៅ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញតាមបណ្តោយផ្លូវជាតិលេខ៤ ចំងាយប្រមាណ១៦គីឡូម៉ែត្រពីវត្តភ្នំ។
សាធារណៈជន និងតំណាងសារព័ត៌មាននានា សូមអញ្ជើញចូលតាមច្រកទ្វាសំរាប់អ្នកចូលទស្សនាដែលស្ថិតនៅប៉ែកខាងកើតនៃបរិវេណអ.វ.ត.ក។

**ការសំរបសំរួលទូទៅ** ៖ ទឹកបរិសុទ្ធមានដាក់នៅផ្លូវចូលនៅខាងក្រៅសាលសវនាការ។ ភេសជ្ជៈ និងអាហារហាមនាំចូលក្នុងសាលសវនាការ។ កញ្ចប់បាយឬអាហារថ្ងៃត្រង់ អាចទិញបាននៅទីនេះ។ បង្គន់អនាម័យមាននៅក្នុងអាគារសវនាការ និងចំណតរថយន្ត។

ចំណតរថយន្ត មានបំរុងទុកសំរាប់អ្នកចូលរួមដែលប្រើមធ្យោបាយផ្ទាល់ខ្លួនរាប់ទាំងរថយន្តក្រុង និងរថយន្តតូច។ ជំនួយសំរាប់ជនពិការក៏មានផ្តល់ជូនផងដែរ រាប់បញ្ចូលទាំងកន្លែងអង្គុយរុញ។

ការចុះឈ្មោះសំរាប់សាធារណៈជនទូទៅ និងសេវាកម្មធ្វើដំណើរសូមទាក់ទងមកកាន់ លោក ជីន ហេមវិចិត្រ
ទូរសព្ទ: (០២៣)២១៩៨១៤ លេខបន្ត:៦០៦៥
ទូរសព្ទដៃ: (០១២) ៦៩៦ ២២០

ទូរសារ: (០២៣) ២១៩៨១៤ លេខបន្ត:៦០៦៩

អ៊ីម៉េល: pas@eccc.gov.kh

សំរាប់ព័ត៌មានបន្ថែមនិងការសំរបសំរួលផ្សេងៗ សូមមើលក្នុងសេចក្តីប្រកាសព័ត៌មានសំរាប់ប្រព័ន្ធផ្សព្វផ្សាយ ឬទាក់ទង លោក ឌឹម សុវណ្ណារុំ តាមរយៈទូរស័ព្ទលេខ ០១២ ៤៨៨ ០៩៤ ឬ  លោកស្រី យូកូ  មេដា តាមរយៈទូរស័ព្ទលេខ ០១២ ៤៨៨  ៣១៩ ។